**សកម្មភាព** ៖ **ល្បែង បត់ក្រដាសជារូបផ្ទះ**

**ចិត្តចលភាព៖** បំណិនចលករតូច៖ កាហ្វឹកហាត់បង្កើនកម្លាំងនិងសម្របសម្រួលរវាងចលនាសាច់ដុំដៃ និងសាច់ដុំភ្នែក។

**គោលបំណង៖**

បំណិនសម្បទា៖កំណត់ចំណុចគោលនៃចលនាដៃដោយការទប់លំនឹងនិងសម្របសម្រួលទៅនឹងភ្នែកក្នុងពេលធ្វើអ្វីមួយ ឬលេងល្បែងបានរឹងមាំល្អ។

**សិក្សាសង្គម៖**

គំនូរនិងសកម្មភាពកសាង៖ ការយល់ដឹងនិងពេញចិត្តចំពោះសិល្បៈតាមរយការបង្កើតជារូបភាពផ្សេងៗ

**គោលបំណង៖**

វិជ្ជាសម្បទា៖ ប្រាប់បានពីរបៀបបត់ រោយ ដេរ ត្បាញ សូនរូប ផាត់ពណ៌ ហែក បិទ បត់ កាត់… ដើម្បីបង្កើតជារូបភាពផ្សេងៗ។

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖ ក្រដាសរាមស ដីខ្មៅពណ៌ ដីខ្មៅ

**កម្រិតសិក្សា** ៖ មធ្យមនិងខ្ពស់

**ការរៀបចំ** ៖ ត្រូវរៀបចំក្រដាសដែលបត់ជាផ្ទះរួចមួយសម្រាប់បង្ហាញទៅកាន់កុមារបានឃើញជាមុនសិន។

**សេចក្តីណែនាំ៖**

1. ប្រាប់កុមារថាថ្ងៃនេះនឹងលេងល្បែងបត់ក្រដាសជារូបផ្ទះដែលមានសមាជិកគ្រួសាររបស់ពួកគេ។
2. សួរសំណួរខ្លះៗទៅកាន់កុមារ ដូចជា៖ កូនៗចូលចិត្តបត់ក្រដាសធ្វើជារូបដែរទេ? កូនៗណាចូលចិត្តលើកដៃ។
3. ល្បែងនេះអាចលេងរៀនៗខ្លួនក៏បាន ដោយចែកក្រដាសរាមសទៅកុមារឱ្យបានគ្រប់ៗគ្នា។
4. ប្រាប់កុមារពីរបៀបបត់ឱ្យបានច្បាស់ជាមុនសិន ឬប្រសិនបើមានពេលគ្រប់គ្រាន់ធ្វើបង្ហាញកុមារនៅពីមុខពួកគេក៏បានដែរ។
    - ❖ ដំបូងយកក្រដាសរាមទំហំ A4 មួយសន្លឹកមកបត់វាជាពីរចំពាក់កណ្តាលឱ្យស្មើគ្នា



- បត់ម្តងទៀតពាក់កណ្តាលទាំងសងខាង ឱ្យស្មើគ្នា (បត់ខាងគែមខ្លី)



- លាតវាចេញទាំងពីរសិន



- សង្កត់បើកទាំងពីរឱ្យមានជាដំបូលសិន



- គូរនិងផាត់ពណ៌ជារូបផ្ទះដែលមានដំបូល បង្អួច ទ្វា ជាដើម…



- រូបសមាជិកគ្រួសាររបស់កុមារនៅខាងក្នុងផ្ទះ ជាការស្រេច។



5. គ្រាន់តែកុមារចេះបត់រូបបែបហ្នឹងជាការស្រេចតែម្តង…។
6. កុមារអាចទុករូបដែលពួកគេបត់បាននៅសាលាឬយកទៅផ្ទះបង្ហាញម៉ាក់ប៉ា របស់ពួកគេក៏បានដែរ។